**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

លេខ ០០៥ សហវ.

# សេចក្តីណែនាំ
# ស្តីពី
# ការដាក់ឱ្យអនុវត្តមុខងាររៀបចំផែនការថវិកា នៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងកិច្ចការនារី

ស្របតាមផែនការសកម្មភាពរួមនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់រាជរដ្ឋាភិបាលកម្ពុជា និង ផែនការពង្រីកការអនុវត្តគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ជំហានទី ៣ (២០២១-២០២៥) ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានអភិវឌ្ឍ និង រៀបចំមុខងាររៀបចំផែនការថវិការួចរាល់ស្របតាមផែនការដែលបានគ្រោងទុក ។ មុខងាររៀបចំផែនការថវិកានេះ នឹងសម្រួលដល់ដំណើរការនៃការរៀបចំផែនការថវិកាឱ្យកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដែលគ្របដណ្តប់ដំណាក់កាលនៃការរៀបចំថវិកា, ការចរចាថវិកា និង ការអនុម័តថវិកា ។ នៅជំហានដំបូងនេះ មុខងាររៀបចំផែនការថវិកា នឹងដាក់ឱ្យអនុវត្តសាកល្បងនៅអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុនៃក្រសួងចំនួន ០២ គឺ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងកិច្ចការនារី មុននឹងបន្តដាក់ឱ្យអនុវត្តជំហានបន្ទាប់ទៅកាន់ក្រសួង-ស្ថាប័នផ្សេងទៀត ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំអំពីការអនុវត្តមុខងាររៀបចំផែនការថវិកា នៃប្រព័ន្ធ FMIS ដូចតទៅ÷

## ១. ការអនុវត្តនៅអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងកិច្ចការនារី

១.១. *អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិរៀបចំគម្រោងថវិកា* ត្រូវលើកគម្រោងថវិកានៅក្នុងប្រព័ន្ធ បន្ទាប់ពីទទួលបានឯកសារគម្រោងថវិកាលម្អិតដែលបានសម្រេចរួចពីក្រសួងរបស់ខ្លួន និង ពិនិត្យឱ្យបានត្រឹមត្រូវ រួចបញ្ជូនគម្រោងថវិកានោះបន្តទៅអ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិជាអ្នកអនុម័ត ។

១.២. *អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិជាអ្នកអនុម័តលើសំណើនៃគម្រោងថវិកា* ត្រូវធ្វើការត្រួតពិនិត្យឱ្យបានហ្មត់ចត់លើសំណើនៃគម្រោងថវិកានៅក្នុងប្រព័ន្ធ ផ្ទៀងផ្ទាត់ជាមួយនឹងឯកសារគម្រោងថវិកាប្រចាំឆ្នាំ រួចធ្វើការអនុម័តលើប្រតិបត្តិការផែនការថវិកានោះនៅក្នុងប្រព័ន្ធដើម្បីបន្តទៅកាន់ដំណាក់កាលបន្ទាប់ ។ បន្ទាប់មក ប្រព័ន្ធនឹងបញ្ជូនគម្រោងថវិកាប្រចាំឆ្នាំរបស់ក្រសួងនីមួយៗ ទៅកាន់អ្នកប្រើប្រាស់នៃអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីបន្តការអនុវត្តនៅដំណាក់កាលបន្តបន្ទាប់ទៀត ។

## ២. ការអនុវត្តនៅអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

២.១. សម្រាប់ផែនការថវិកានៃក្រសួងទាំងពីរខាងលើ, បន្ទាប់ពីទទួលបានការសម្រេចនៅក្នុងដំណាក់កាលប្រជុំចរចាថវិកាកម្រិតបច្ចេកទេស និង ដំណាក់កាលប្រជុំចរចាថវិកាកម្រិតថ្នាក់ដឹកនាំជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរួចហើយ *អ្នកប្រើប្រាស់ប្រព័ន្ធនៃអគ្គនាយកដ្ឋានថវិកា ដែលទទួលសិទ្ធិកែសម្រួលប្រតិបត្តិការផែនការថវិកានៅក្នុងប្រព័ន្ធ* ត្រូវធ្វើការពិនិត្យ និងកែសម្រួលលើប្រតិបត្តិការផែនការថវិការបស់ក្រសួងនីមួយៗតាមវិស័យដែលខ្លួនទទួលបន្ទុក ទៅតាមដំណាក់កាលនៃការចរចានីមួយៗដោយឡែកពីគ្នា និង បញ្ជូនប្រតិបត្តិការផែនការថវិកានោះបន្តទៅអ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិជាអ្នកអនុម័តសំណើនៃគម្រោងថវិកាតាមវិស័យនៅក្នុងដំណាក់កាលនីមួយៗដោយឡែកពីគ្នា ។ ដោយឡែក សម្រាប់ក្រសួង-ស្ថាប័នផ្សេងទៀត ដែលមិនទាន់បានដាក់ឱ្យអនុវត្តមុខងាររៀបចំផែនការថវិកានេះ *អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិបង្កើត*

*ប្រតិបត្តិការផែនការថវិកានៃអគ្គនាយកដ្ឋានថវិកា* នឹងធ្វើការបញ្ចូលផែនការថវិកាដែលទទួលបានការអនុម័តចុងក្រោយ (ច្បាប់ថវិកា) ទៅក្នុងមុខងាររៀបចំផែនការថវិកាតែម្តង ។

២.២. *អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិអនុម័តលើសំណើនៃគម្រោងថវិកាតាមវិស័យ* ត្រូវធ្វើការត្រួតពិនិត្យ សំណើនៃគម្រោងថវិកានៅក្នុងប្រព័ន្ធដែលបានកែសម្រួលរួច នៅក្នុងដំណាក់កាលនីមួយៗនៃចំណុច ២.១ ខាងលើ និង ផ្ទៀងផ្ទាត់ឱ្យបានហ្មត់ចត់នូវគម្រោងថវិកាដែលបានសម្រេចនៅក្នុងដំណាក់កាលនីមួយៗនៃការចរចាថវិកា រួចធ្វើការអនុម័តគម្រោងថវិកានោះទៅតាមដំណាក់នីមួយៗដោយឡែកពីគ្នា ។ បន្ទាប់ពីបញ្ចប់ដំណាក់កាលនៃការចរចាថវិកាកម្រិតថ្នាក់ដឹកនាំ ប្រព័ន្ធនឹងបញ្ជូនគម្រោងថវិកាបន្តទៅកាន់ដំណាក់កាលបន្ទាប់ ។

២.៣. *អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិកែសម្រួលប្រតិបត្តិការផែនការថវិកា* សម្រាប់ដំណាក់កាលបន្ទាប់ពីបញ្ចប់កិច្ចប្រជុំចរចាថវិកាកម្រិតថ្នាក់ដឹកនាំ ត្រូវធ្វើការកែសម្រួលប្រតិបត្តិការផែនការថវិកានៅក្នុងប្រព័ន្ធទៅតាមដំណាក់កាលដោយឡែកពីគ្នា ផ្អែកលើលទ្ធផលនៃការអនុម័តថវិកាក្នុងដំណាក់កាលនីមួយៗ រួមមាន ការអនុម័តរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ការអនុម័តរបស់រដ្ឋសភា និង ការអនុម័តរបស់ព្រឹទ្ធសភា រួចបញ្ជូនបន្តទៅកាន់អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិអនុម័តគម្រោងថវិកាទៅតាមដំណាក់កាលនីមួយៗ ។

២.៤. *អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិអនុម័តគម្រោងថវិកា* សម្រាប់ដំណាក់កាលបន្ទាប់ពីបញ្ចប់កិច្ចប្រជុំចរចាថវិកាកម្រិតថ្នាក់ដឹកនាំ ត្រូវបន្តធ្វើការត្រួតពិនិត្យគម្រោងថវិកានៅក្នុងប្រព័ន្ធដែលបានកែសម្រួលរួច និង ផ្ទៀងផ្ទាត់ឱ្យបានហ្មត់ចត់ជាមួយនឹងគម្រោងថវិកាដែលបានអនុម័តនៅក្នុងដំណាក់កាលនីមួយៗនៃចំណុច ២.៣ ខាងលើ រួចធ្វើការអនុម័តគម្រោងថវិកានោះនៅក្នុងប្រព័ន្ធ ទៅតាមដំណាក់នីមួយៗដោយឡែកពីគ្នា ។ បន្ទាប់ពីបញ្ចប់ការអនុម័តនៅក្នុងប្រព័ន្ធនៅគ្រប់ដំណាក់កាល ប្រព័ន្ធនឹងបញ្ជូនគម្រោងថវិកាបន្តទៅអ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិអនុម័តចុងក្រោយ ។

២.៥. អ្នកប្រើប្រាស់ប្រព័ន្ធដែលទទួលសិទ្ធិអនុម័តច្បាប់ថវិកានៅក្នុងប្រព័ន្ធ ត្រូវធ្វើការអនុម័តទៅលើច្បាប់ថវិកាប្រចាំឆ្នាំនៅក្នុងប្រព័ន្ធ ដើម្បីបញ្ចប់ដំណើរការនៃការរៀបចំផែនការថវិកាប្រចាំឆ្នាំនៅក្នុងប្រព័ន្ធ ។

អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងកិច្ចការនារី, អគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង អង្គភាពពាក់ព័ន្ធផ្សេងទៀត ត្រូវអនុវត្តតាមសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

*ថ្ងៃព្រហស្បតិ៍ ៦រោច ខែបឋមាសាឍ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស. ២៥៦៥*

*រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែកក្កដា ឆ្នាំ ២០២១*

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**<u>កន្លែងទទួល៖</u>**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី

"ដើម្បីជូនជ្រាប"

- ក្រសួងកិច្ចការនារី
- អគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

"ដើម្បីអនុវត្ត"

- ឯកសារ-កាលប្បវត្តិ

**លំហូរនៃការប្រើប្រាស់មុខងាររៀបចំផែនការថវិកានៃប្រព័ន្ធ FMIS**

*១. <u>លំហូរនៃការរៀបចំផែនការថវិកាពីក្រសួងទាំងពីរមកដល់ការសម្រេចពីកិច្ចប្រជុំកម្រិតថ្នាក់ដឹកនាំ</u>*



## ២. លំហូរនៃការរៀបចំផែនការថវិកាពីការអនុម័តរបស់ទីស្តីការគណៈរដ្ឋមន្ត្រីរហូតដល់ច្បាប់ថវិកាប្រចាំឆ្នាំ

